# ពាក្យពេចន៍ខ្លះគួរពិចារណា

## សម្រង់ចាកសៀវភៅប្រមូលភាសិតខ្មែរ

### ស្រាវជ្រាវ ចងក្រង និង ចេញផ្សាយដោយៈ **សមាគមសម្ដេច ជួន ណាត**

១. កុំជិះចង្កេរលើកខ្លួនឯង ក្បាលទូលកញ្ជ្រែងកុំក្អេងក្អាង កុំដេកទទូរចាំសំណាង កុំអាងព្រះប្រោសត្រូវតែប្រឹង។

២. ខ្មាសលួង់ទើបចេះ ខ្មាសក្រទើបមាន។

៣. ត្រូវខំរកស៊ីខំធ្វើការ មុខមិនអសារឥតប្រយោជន៍ បើចង្រៃណាស់ក៏យ៉ាងហោច គង់បានគ្រប់ស៊ីមិនសុំគេ។ ប្រសិនជាបើមានសំណាង ដែលបានកសាងពីបុព្វេ ផ្សំផ្សំមកផងមិនលេងទេ អាចនឹងឡើងដល់ជាសេដ្ឋី។

៤. គុកនិងសោរចោរបង្កើត ឱសថល្អធើតកើតពីរោគ ដំណេកកើតពីការងុយងោក វាសនាមនុស្សលោកកើតពីកម្ម។

៥. ឃាត់កំហឹងដោយការប្រឹងអត់ធ្មត់ ឃាត់ពាលស្មុគទ្រុឌដោយប្រើអាជ្ញា បុគ្គលណាអាចឃាត់ចិត្តចាកទោសា រាប់ថាថ្លៃថ្លាប្រសើរក្នុងលោកិយ។

៦. ឃាត់ចិត្តឱ្យចាកក្ដីស្នេហា នៅក្នុងតណ្ហានាលោកិយ ដូចយកអំបោះចងដំរី ពិបាកពេកក្រៃនឹងធ្វើបាន។

៧. សេពគប់ជន់ពាល រាលទុក្ខដល់ខ្លួន។

៨. ឃើញគេទៅកុំឱ្យខាន ឃើញគេបានកុំឱ្យទៅ។

៩. ឃើញខ្លាដេកកុំថាខ្លាស្លាប់ ឃើញខ្លាក្រាបកុំថាខ្លាសំពះ។

១០. ឃើញឈើពុក កុំអាលដាក់គូទអង្គុយ។

១១. ឃើញពីនាយកុំអាលទាយអាក្រក់ល្អ លុះឃើញជាក់ជាខ្មៅសទើបថាបាន បើបណ្ដោយតាមគំនិតដែលគិតស្មាន នឹងវិនាសព្រោះការខុសកំហុសខ្លួន។

១២. ឃ្មុំកន្លង់រៀបរង់ឈើគ្មានផ្កា សត្វម្រឹគារៀបរង់ព្រៃភ្លើងឆេះ។

១៣. ឆ្ងាញ់មិនឆ្ងាញ់អាស្រ័យលើគម្លាន ល្អអាក្រក់ទាំងប៉ុន្មានអាស្រ័យលើចិត្ត។

១៤. ងប់នឹងញាតិឃ្លាតច្បាប់ ងប់នឹងពាក្យបង្គាប់ស្លាប់គំនិត។
ងប់នឹងប្រុសអស់ព្រហ្មចារីយ៍ ងប់នឹងស្រីចំណីទុក្ខ។
ងប់នឹងល្បែងតែងតែភ្លើ ងប់នឹងពាក្យសរសើរតែងតែភ្លាត់។

១៥. ងាប់នឹងសម្តីដូចត្រីកំភ្លាញ ងាប់នឹងអាចម៍ឯងដូចខ្វែក។

១៦. ចងអ្វីមិនជាប់ស្មើសង្សារ ការអ្វីមិនស្មើប្រតិបត្តិ ស្ងាត់អ្វីមិនស្មើចិត្តអរហត្ត កាចអ្វីមិនស្មើចិត្តពាលា។

១៧. ចងទូកបោះបង្គោល រិះរកថ្នោលព្រួយឃុំថ្កា ការខ្យល់ព្យុះកាចជា ក្រែងពានពារបោកបែកបាត់។

១៨. ចងចិត្តជនលោភដោយឱ្យធន ចងបណ្ឌិតជនដោយពាក្យសត្យ ចងអ្នកឆ្មើងឆ្មៃដោយប្រណិប័តន៍ ចងអ្នកល្ងង់ក្តាត់ដោយបណ្តោយតាម។

១៩. ចង់ដឹងភាពមនុស្សមើលសេពគប់ ចង់ដឹងភូមិភពដោយទស្សនា ដឹងពាលបណ្ឌិតដោយចរិយា ចង់ដឹងអាត្មាត្រូវអប់រំ។

២០. ចង់គង់ឱ្យទុក ចង់បានក្តីសុខឱ្យដើរស្វែងរក។

២១. ចង់បានសុខតត្រុកចូលក្រុមភាគច្រើន មិនក្រវើនមើលមុខក្រោយឱ្យច្បាស់ការណ៍ ព្រតែផ្តរចាក់ទឹកចោលបង់អសារ ដល់គ្មានភ្លៀងរត់ឆ្វេឆ្វារកទឹកគ្មាន។

២២. ចង់ធំឱ្យខំពីតូច បើខ្លាចខូចកុំឆាប់ខឹង ការអ្វីឱ្យចេះថ្លឹង កុំប្រឹងជុះតាមដំរី។

២៣. ចងធំឱ្យតូច ចង់ខ្ពស់ឱ្យទាប ចង់បានឱ្យបង់ ចង់ចេះឱ្យរៀន។

២៤. ចង់ល្អហួសមាឌ ចង់បានហួសខ្នាត កម្រិតតម្រា មិនបានដូចប៉ង បំណងប្រាថ្នា ខូចទាំងទ្រព្យា គួរបានក៏បង់។

២៥. ចង់បានហួសខ្នាត ច្រើនតែបង់ខាត ខកខូចលាភា ខាតបង់ចំណេញ ច្រើនហួសមាត្រា ដូចពាក្យចាស់ថា លោភវែងបាត់ធន។

២៦. ចង់ច្រើនបានតិច ប្រឹងដើរវិលវេច បានខាតទទេ ខំចេញជួញឆ្ងាយ ពុំបានទំនេរ ប្រែខាតបង់កេរ្តិ៍ ដើមទុនចេញទៅ។

២៧. ចង់ប្រាជ្ញឱ្យប្រឹង ចងក្បិនតឹងរកស៊ីធូរ គំនិតមុនគំនូរ រៀនធ្វើគ្រូមានគេរាប់។

២៨. ចាប់ត្រីដៃពីរតម្រាហាម ចាក់អង្ករយកអង្កាមព្រោះមានះ ដូចអុំទូកឡើងភ្នំខំមិនឈ្នះ បន់ព្រះទៅសំពះឯបាយាប (អារក្សទឹកសម្រាប់ពួកអ្នកនេសាទមច្ឆជាតិគោរព)។

២៩. ចាបមួយនៅដៃប្រសើរក្រៃ ជាងចាបដប់ម្ភៃនៅលើមេឃ។

៣០. ចាស់ថានៅស្រុកឱ្យស្រះបន្លា អារសាច់ជូនខ្លាកុំខ្លាចស្តាយ វិជ្ជានឹងកើតមកពីកាយ កុំណាយខ្លាចនឿយគិតឱ្យយូរ។

៣១. ចិញ្ចឹមមនុស្សខូច ដូចចិញ្ចឹមកូនខ្លា។

៣២. ចិញ្ចឹមមនុស្សឱ្យមើលចិត្ត ចិញ្ចឹមសត្វឱ្យមើលចង្កូម។

៣៣. រីចិត្តមនុស្សលោកដូចសាគរធំ ទន្លេប្រជុំពុំចេះស្កប់ស្កល់ ទោះបីមានទ្រព្យនៅសេសសល់ គង់នៅកិច្ចកលពោលថាក្រ។

៣៤. ចិត្តចង់កុំអាលធី ឃើញតែស្រីកុំអាលចង់។

៣៥. និរាសកុំម្នេញ ខឹងកុំទន្ទេញ ស្អប់កុំព្យាបាទ។

៣៦. ចេកស្លាប់ព្រោះផ្លែ ដំរីស្លាប់ព្រោះភ្លុក។

៣៧. ចេញពីខ្លួនមិនទាន់ធួននៅឡើយទេ ត្រូវគ្នាន់គ្នេរយកពីគេមកផ្សំផង ទើបការនោះបានបែបបទល្អហ្មត់ហ្មង តាមបំណងប៉ងប្រាថ្នាក្នុងការល្អ។

៣៨. ចេះមួយចេះពីរឱ្យតែស្ទាត់ ប្រកបប្រាកដអ្នកចំណាន ជាហេតុចិញ្ចឹមជីវិតបាន សន្តានចូលពឹងពំនឹងអើយ។

៣៩. ចេះច្បាប់មិនខ្លាចក្តី ចេះវិន័យមិនខ្លាចអាបត្តិ (ទោសដែលភិក្ខុត្រូវព្រោះកន្លងឬល្មើសពុទ្ធប្បញ្ញត្តិ)។

៤០. ចេះមិនឈ្នះចង់។

៤១. ចេះមែនហើយតែនៅឡើយមិនទាន់ចេះ ព្រោះចំណេះច្រើនលើសលប់គ្រប់បែបយ៉ាង នឹងគណនារាប់មិនបានមានជាតាង កុំអាលអាងថាចេះចប់សព្វអស់ហើយ។

៤២. ចោរព្រៃហ៊ានដោយសារចោរស្រុក ខ្មោចក្រៅលុកព្រោះខ្មោចក្នុងញ៉ាំង ប្រទេសក្រៅមិនហ៊ានចូលមកច្បាំង បើគ្មានខ្មាំងក្នុងស្រុកក្បត់ឱ្យដៃ។

៤៣. ចៅហ្វាយមានបុណ្យខុនមានស័ក្តិ ចៅហ្វាយអប្បលក្ខណ៍ខុនធ្លាក់តតួង។

៤៤. ចំបាប់នឹងលោកសង្ឃ ខ្លាចអ្វីនឹងកាន់ព្រះកេស។

៤៥. ចំណីឆ្ងាញ់កុំទុកស្អែក ប្រពន្ធល្អប្លែកកុំឱ្យដើរក្រោយ។

៤៦. ចំពោះជនមានចំណេះចេះវិជ្ជា គួរនាំគ្នាស្ញើចសរសើរគេទៅចុះ ចំណែកជនគ្មានវិជ្ជាគ្នាធ្វើខុស កុំបន្ទុះគួរមេត្តាករុណាផង។

៤៧. ចំណេះវិជ្ជាលោកចែងចាត់ ទុកជាសម្បត្តិសម្បូរបាន ទោះបីក្រខ្សត់អត់ប៉ុន្មាន គង់តែបានគ្រាន់នឹងអាស្រ័យ។

៤៨. ច្បាប់ពុំឈ្នះមនុស្សពាលនិងកាំភ្លើង គួរតែយើងកុំទទឹងរឹងខ្វាយខ្វល់ គួរបណ្តោយឱ្យខ្លែងហើរទៅតាមកល តែអស់ខ្យល់មុខជាធ្លាក់ជាក់ប្រាកដ។

៤៩. ឆ្លៀតកេងកិបចំពោះអ្នកឱ្យផល ដោយប្រើកលគំនិតគិតថោកថាគេមិនដឹង អំពើឆបោកបែបនេះលោកថាប្រៀបដូចប្រឹង ខំទទឹងចាប់បោកឆ្នាំងបាយឯង។

៥០. ឆ្អិនឆ្ងាញ់យ៉ាងណាកុំសារ៉ាភ្លេចកាលឆៅ ធម្មតាឆ្អិនទើបកើតក្រោយដោយសារក្តៅ បើគ្មានឆៅតើបានឆ្អិនមកពីណា។

៥១. ជនឯណាមានមាត់ក្រអូបដូចបទុម ពាក្យកិរម្យដូចជាតិច័ន្ទន៍ត្រជាក់ តែក្នុងពោះមានពិសមុតដូចចក្រ ជននោះគួរកុំស្ម័គ្រស្មាគមឡើយ។

៥២. ជនណាពោលភាសាជទៃស្និទ្ធ យូរទៅជាប់ចិត្តភ្លេចពាក្យខ្លួន ភ្លេចជាតិសាសនានិងច្បាប់ក្បួន ដូចក្រពើចួនវង្វេងបឹង។

៥៤. ជនណាដឹងគួរសម ដឹងកិរម្យពោលពាក្យពិត មិនខឹងក្រោធក្រៅក្រឹត្យ អ្នកនោះពិតបណ្ឌិតជន។

៥៥. ជនដែលប្រាសចាកគុណ ចាត់ថាស៊ុនអាប់យស ទោះមានត្រកូលខ្ពស់ នឹងមានយសក៏មិនសម។

៥៦. ជនដែលធ្វើអំពើល្អបរិសុទ្ធស្អាត មិនប្រមាទធ្វេសប្រហែសការគ្រប់យ៉ាង ជននោះតែងសត្រូវនឹងពួកម្ខាង ដែលកសាងតែកម្មពៀរជាអកុសល។

៥៧. ជាតិមនុស្សទោះថោកទាប មិនចោលភាពពីម៉ែឪ ពាក្យមនុស្សវែងជាងផ្លូវ ស្រូវច្រើនខួបខូចអង្ករ។

៥៨. ជួញខាតកុំឈប់ខាន បើចង់បានកុំខ្លាចបង់ ខ្លាចបាត់ឱ្យផ្ចិតផ្ចង់ ប្រុងថែទាំឱ្យមាំមួន។

៥៩. ជ្រៃលោមស្រឡៅ ត្រាវលោមបឹង។

៦០. ជ្រៅទឹកជ្រៅដីមិនជាជ្រៅអ្វីគង់មានទៅដល់ ឯជ្រៅគំនិតជ្រៅឆ្ងាយពិតសែនសល់ ជ្រៅទៅមិនដល់គ្មានទីបំផុត។

៦១. ជ្រះថ្លាក្នុងការល្អ គួរត្រេកអរជ្រះថ្លាចុះ ជ្រះថ្លាក្នុងការខុស កុំបណ្ដោះជ្រះថ្លាឡើយ។

៦២. ពេលឈឺធ្ងន់យកដំរីទៅបន់ ដល់ពេលស្រន់យកពងមាន់ទៅថ្វាយ។

៦៣. ឈើធំរលំឮខ្លាំង។

៦៤. ឈើល្អផ្កាក្រអូបសូម្បីមួយដើម អាចស្រង់ក្លិនផ្សើមឈ្ងុយសព្វព្រៃ ដូចត្រកូលដែលមានកូនល្អប្រពៃ
បានជាសិរីនៃវង្សញាតិផៅ។

៦៥. ឈ្នួញទឹកពឹងទូក រីឈ្នួញគោកពឹងរទេះ សំណាងពឹងចំណេះ ប្រាជ្ញប្រាយចេះពឹងគម្ពីរ។

៦៦. ឈ្លោះនឹងពាលឃើញពិបាកបន្តិចហើយ កុំស្មានឡើយថាពាលស្ដាប់ស័ព្ទវាចា ទុកជាវែកញែករកខុសត្រូវទៅផ្លូវណា
ក៏ពាលថាគេមិនស្ដាប់ច្បាប់អ្វីទេ។

៦៧. ឈ្នះអ្នកស័ក្តិខ្ពស់ដោយលុតក្រាប ឈ្នះអ្នកទន់ទាបដោយឱ្យទាន បំបែកសាមគ្គីឈ្នះអ្នកក្លាហាន
ឈ្នះអ្នកស្មើប្រាណដោយព្យាយាម។

៦៨. ឈ្លោះគ្នាក្នុងគ្រួសារ ដូចស្រាតកាយាបង្ហាញញាតិ ឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណប់បង្ហាញចោរ។

៦៩. ញញឹមស្មើ សើចស្មើរ សម្ដីពិរោះ ការណ៍ទាំងនេះចូរប្រយ័ត្ន។

៧០. ញញួរប្រើកើតព្រោះមានដង អ្នកផងបានខ្ពស់ព្រោះអ្នកធំ ដូចពេជ្រមានមាសប្រាក់ស្រោបរុំ
ទើបបានឧត្ដមស្គាល់ថាពេជ្រ។

៧១. ញាតិនិងមិត្ត បើញាតិមិនគិត មិត្រប្រសើរជាង។

៧២. ដល់ក្របីបាត់ទើបធ្វើរបង ដល់ពេលប្រលងទើបស្វាធ្យាយ ដល់ពេលចេញដើរទើបវេចសម្ពាយ
បីនេះអន្តរាយវិនាសបង់។

៧៣. និយាយស្ដីឱ្យមើលតម្រា និយាយការឱ្យមើលទំនង។

៧៤. ដាវមុត មុតមែននៅក្នុងស្រោម វិជ្ជាចេះព្រមនៅក្នុងក្បួន ប្រពន្ធគាប់ចិត្តនៅឆ្ងាយខ្លួន ដល់ចួនត្រូវការរអារចិត្ត។
៧៥. ដឹងថាខ្លួនល្ងង់ គង់បានជាប្រាជ្ញ។

៧៦. ដើរជិតផ្ទះគេពេលគេដេក កុំក្អេងក្អាងពេកគេផ្អើលភ្ញាក់ និយាយឱ្យល្មមគេស្តាប់ជាក់ កុំខ្សឹបលបលាក់គេសង្ស័យ។

៧៧. ដេកកុំដំដើច គេក្រកុំសើច គេភ័យកុំព្យួរហ៍ ទោះខឹងប៉ុន្មាន ធ្វើជាឱ្យគួរ តឹងគិតឱ្យធូរ យូរគិតឱ្យឆាប់។

៧៨. ស្ថានសួគ៌មាននៅក្នុងលោកិយ គឺជនប្រុសស្រីក្នុងគ្រួសារ ចេះស្រុះស្រួលគ្នារាល់វេលា ទោះខ្ទមជរាក្លាយជាប្រាសាទ។

៧៩. រស់យូរឥតអំពើ បើមិនធ្វើអំពើល្អ។

៨០. ណាត់ជួបជុំគ្នាពេលម៉ោងណា ត្រូវប្រុងកាយាកុំឱ្យខាន ត្រូវគិតអៀនខ្មាសមាន់តិរិច្ឆាន វារងាវបានទៀងគ្រប់ពេល។

៨១. ណែនាំកូន ត្រូវប្រដៅខ្លួនទុកជាគំរូ។

៨២. តែខំប្រមាថវាបាត់បុណ្យ ចិត្តជួស្នូរជេនបាត់សទ្ធា មានៈបាត់មិត្រឥតគ្នីគ្នា វិជ្ជានិងចេះមកពីចិត្ត។ តែខំរៀនច្រើនកើនចំណេះ តែចេះការច្រើនជាបច្ច័យ តែខំរៀនសូត្ររាល់ខែថ្ងៃ ដូចថ្នៃត្បូងពេជ្រលេចពន្លឺ។

៨៣. តែចេះពេកតែឆ្លាតពេកគេស្អប់ គេត្រលប់ជាថាឯងសម្តែងឫទ្ធិ គេមិនតាំងចិត្តបំណងប៉ងជាមិត្ត គេមិនគិតថាឯងល្អបរិសុទ្ធទេ។

៨៤. តែនិយាយផ្លោយពីមាត់ទៅហើយ កុំគិតឡើយថាមិនចូលត្រចៀកគេ តែមានខ្លួនកុំគិតពួនមិនបាត់ទេ មុខតែគេមើលឃើញស្តែងមិនលែងឡើយ។

៨៥. តែខ្សោយវិជ្ជាវាខ្សត់ធន តែបុណ្យស័ក្តិគ្មានខ្មាសអៀនប្រាណ។

៨៦. ត្រូវប្រើសត្រូវកំចាត់សត្រូវ ដោយឱ្យទ្រព្យត្រូវដល់ចិត្តវា ដូចបន្លាមុតក្នុងបាទា យកបន្លាដូចគ្នាជួសទើបបាន។

៨៧. ត្រូវយកដើមត្រែងជាច្បាប់ប្រាណ វាយោបក់ច្រានមិនរលំ រុក្ខជាតិដូចយ៉ាងធ្មឹកសុក្រំ ខ្យល់ធំបក់ចំគង់រលើង។

៨៧. ត្រូវថ្នមកូនដល់អាយុប្រាំវស្សា ត្រូវវាយជេរថាទៅត្រឹមដប់ឆ្នាំ ដល់អាយុដប់ប្រាំមួយចូរចាំ ពាក្យអ្នកប្រាជ្ញផ្តាំថាកូនជាមិត្រ។

៨៨. ត្រៀបត្រាដូចឃ្លោកត្រឡាច គ្មានអង់អាចស្គាល់ខុសត្រូវ។

៨៩. ថ្លង់ចង់ស្តាប់ច្រៀង ផ្អៀងផ្អងផ្ទៀងផ្ទាប់ ដៃខ្វីខ្លួនទាបចង់ឈោងចាប់ផ្កាយ។

៩០. ថ្លៃមានថ្លៃពេជ្រ មិនមែនថ្លៃផ្កាច់ នៅក្នុងលោកិយ ថ្លៃឫកមារយាទ ទើបថ្លៃពិសី ថ្លៃឥតមានអ្វី ប្រៀបផ្ទឹមស្មើបាន។

៩១. ទឹកខ្លាចគេដងដាក់តម្កល់ ជាតិដែកដុលខ្លាចគេជំនៅ ក្រញូងខ្លាចធ្វើខ្ទួចក្បួចដូចស្មៅ ទូកខ្លាចគេទៅជាន់តែមផ្ទៀង។

៩២. ទឹកថ្លាលាងសក់ ទឹកល្អក់លាងជើង។

៩៣. ទូកហួសកំពង់ អាចចែវបង្អង់ ថយមកចូលចាប់ ពាក្យលឿនហួសខ្នាត ហៅឥតគំនាប់ ថយមករកគាប់ ពុំបានឡើយណា។

៩៤. ទោសតិចកុំទាញផ្សំ ឃើញមិនចំកុំនិយាយ កុំចាប់ស្នើររាយមាយ នាំឱ្យរវល់អំពល់ចិត្ត។

៩៥. ទ្រព្យសប្បុរស ទោះតិចតួចគង់បានជាប្រយោជន៍ដល់ជននានា ដូចទឹកអណ្តូងរសសាបថ្លា អស់មហាជនផងដងអាស្រ័យ។ ទ្រព្យអសប្បុរស ទោះមានច្រើនក៏ពុំចម្រើនដល់អ្នកដទៃ ដូចទឹកសមុទ្រមានច្រើនក្រៃ តែមានជាតិប្រៃ មនុស្សផងអាស្រ័យមិនបាន។

៩៦. ទ្រព្យកើតក្រោយកិរិយា បើរកកិរិយាឱ្យរើសមារយាទ ក្រទ្រព្យមាសប្រាក់បញ្ញាឆ្លាត ហៅមានតាមខ្នាតគង់ពកស្នែង។

៩៧. ធម្មជាតិជ្រែបញ្ញើក្អែក ទំនើលើមែកឈើព្រឹក្សព្រៃ ជញ្ជក់យករសឥតប្រណី ទាល់តែក្សិណក្ស័យវិនាសបង់។

៩៨. ធ្ងន់អំរែកជួយគ្នាបាន ធ្ងន់ជំងឺក្នុងប្រាណជួយមិនបានទេ។

៩៩. បើធ្វើស្រែគេយកស្រូវ បើគាបអំពៅគេយកស្ករជាតិ បុគ្គលជួយយើងប្រាថ្នាសង្វាត កំរែតាមខ្នាតមិនមែនទទេ។

១០០. នរណាអេះ! ចេះផ្គាប់មនុស្សត្រូវគ្រប់គ្នា កុំបីមានគេនិន្ទាឈ្នានីសបាន ឱ្យគាប់ចិត្តស្និទ្ធសេពគប់គ្រប់ៗប្រាណ ជឿថាគ្មានដល់ទៅម្នាក់ជាក់មែនហើយ។